THE SCHOOL DISTRICT OF PHILADELPHIA

ការិយាល័យអគ្គនាយកក្រសួងអប់រំ
440 North Broad Street
Philadelphia, PA 19130

**Dr. Tony B. Watlington Sr., Ed.D.**
អគ្គនាយកក្រសួងអប់រំ

ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ ២០២៣

ជូនចំពោះ មាតាបិតា និងអាណាព្យាបាលរបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ៉ា៖

**ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា (Philly School Experience Survey) សម្រាប់មាតាបិតា និងអាណាព្យាបាល** ដែលពីមុនហៅថា ការស្ទង់មតិទូទាំងក្រសួងប្រចាំឆ្នាំ សម្រាប់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ៉ា **បើកហើយឥឡូវនេះ!** ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា (The Philly School Experience Survey) គឺជាឧបករណ៍ដ៏ល្អបំផុតមួយដែលយើងមាន ដើម្បីប្រមូលមតិកែលម្អរបស់លោកអ្នក និងវាយតម្លៃទស្សនៈរបស់លោកអ្នកលើប្រធានបទជាច្រើនដែលជះឥទ្ធិពលដល់បទពិសោធន៍អប់រំសម្រាប់សិស្ស។ ការឆ្លើយតបរបស់លោកអ្នកជួយយើងវាស់ស្ទង់ការរីកចម្រើនទៅកាន់ គោលដៅទាក់ទងនឹងការសិក្សាដែលមានជោគជ័យ និង ល័ក្ខខ័ណ្ឌដែលត្រូវមានដើម្បីឲ្យសិស្សមានជោគជ័យ របស់ក្រុមប្រឹក្សាភិបាលអប់រំ (Board of Education's Goals & Guardrails) និងកែលម្អសាលា និងសេវាកម្មរបស់យើង តាមវិធីផ្សេងៗ រួមទាំង – ការជូនដំណឹងអំពីផែនការសាលា និងអាទិភាពផ្តល់មូលនិធិប្រចាំឆ្នាំ បញ្ជាក់ពីធនធាននៅក្នុងសហគមន៍ដែលសិស្ស និងក្រុមគ្រួសារត្រូវការ និងអ្វីៗជាច្រើនទៀត។

**តើមានអ្វីថ្មីនៅឆ្នាំនេះ**?

- **ការស្ទង់មតិមានឈ្មោះថ្មី។** ការស្ទង់មតិទូទាំងក្រសួងប្រចាំឆ្នាំ ឥឡូវនេះហៅថា ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា (PSES) ដើម្បីឆ្លុះបញ្ចាំងឱ្យបានល្អប្រសើរជាងនេះថា *ជាការស្ទង់មតិអំពី*សហគមន៍សាលា និងសម្រាប់សហគមន៍សាលា។

- **ការស្ទង់មតិនេះគឺអនាមិក។** ការស្ទង់មតិរបស់ មាតាបិតា/អាណាព្យាបាល តែងតែរក្សាទុកជាការសម្ងាត់បំផុត ប៉ុន្តែឆ្នាំនេះវាក៏ជាអនាមិកផងដែរ មានន័យថា គេនឹងមិនស្នើសុំលោកអ្នកឱ្យសរសេរអត្តលេខរបស់សិស្សទេ។

- **ការស្ទង់មតិនេះត្រូវបានបង្រួញ។** ការស្ទង់មតិរបស់ មាតាបិតា/អាណាព្យាបាល អាចបំពេញរួចរាល់ប្រហែល ៥ ទៅ ៧ នាទី។

លោកអ្នកអាចចូលទៅកាន់ ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា នៅទីនេះ ។ ដើម្បីបង្ហាញការថ្លែងអំណរគុណរបស់យើង អ្នកណាម្នាក់ដែលបំពេញការស្ទង់មតិតាមអ៊ិនធ័រណិត អាចបញ្ចូលឈ្មោះ

ទៅក្នុងការចាប់ឆ្នោតអំណោយ សម្រាប់ឱកាសឈ្នះប័ណ្ណអំណោយអេឡិចត្រូនិច ចំនួន ២៥ ដុល្លារ។ យើងខ្ញុំស្នើសុំការឆ្លើយតបមួយក្នុងមួយគ្រួសារ សម្រាប់សាលានីមួយៗដែលសិស្សរបស់លោកអ្នកទៅរៀន។

**ពេលវេលានៃ ការស្ទង់មតិអំពីបទពិសោធន៍ជាមួយសាលាក្នុងទីក្រុងហ្វីឡា បិទនៅ ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០២៣។** ប្រសិនបើលោកអ្នកមានបញ្ហាក្នុងការ ចុចចូល (**logging in**) ឬមានសំណួរអំពីការស្ទង់មតិនេះ សូមផ្ញើអ៊ីមែលទៅក្រុមស្ទង់មតិ តាមរយៈ schoolsurveys@philasd.org។ សម្រាប់ព័ត៌មានបន្ថែមអំពីការស្ទង់មតិទូទាំងក្រសួង រួមទាំងលទ្ធផលកាលពីឆ្នាំមុន សូមចូលទៅកាន់គេហទំព័រ www.philasd.org/PSES។

ខ្ញុំសុំឱ្យលោកអ្នកឆក់យកអត្ថប្រយោជន៍ពីឱកាសនេះ ដើម្បីបញ្ចេញសម្លេងរបស់លោកអ្នកឱ្យគេដឹងឮ។ សូមអរគុណចំពោះការបញ្ចេញសម្លេងដើម្បីកូនរបស់លោកអ្នក!

ដោយសេចក្តីស្មោះស្ម័គ្រ

Tony

Tony B. Watlington Sr., Ed.D.
អគ្គនាយកក្រសួងអប់រំ
ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា